សារព័ត៌មាន

# ខ្មែរម្ចាស់ស្រុក

Khmer Machas Srok News

សារព័ត៌មានចេញផ្សាយប្រចាំថ្ងៃ

ឆ្នាំទី ០៣ លេខ ៥៥៤ ចេញផ្សាយថ្ងៃ អាទិត្យ-ចន្ទ ទី ១៣-១៤ ខែ ធ្នូ ឆ្នាំ ២០០៩

## គណបក្សសមរង្ស៊ីបន្តប្រមូលស្នាមមេដៃរាស្ត្រសុំទៅព្រះមហាក្សត្រ រកការប្រគល់អភ័យឯកសិទ្ធិសភាជូនលោកសមរង្ស៊ីវិញ


លោក សម រង្ស៊ី មេដឹកនាំគណបក្សប្រឆាំងដ៏ធំជាងគេក្នុងប្រទេសកម្ពុជា


លោក យឹម សុវណ្ណ អ្នកនាំពាក្យគណបក្សសមរង្ស៊ី


លោក សម រង្ស៊ី ពេលដកតម្រុយឈើ៦ដើមនៅស្រុកចន្ទ្រា ខេត្តស្វាយរៀង


ចារកម្មសៀម ស៊ីវ៉ារ៉ាក់ ជុធិពង់ ត្រូវព្រះមហាក្សត្រខ្មែរព្រះរាជទានលើកលែងទោស

ដោយ : គ.អរពិន្ទ

ការវិវឌ្ឍន៍ថ្មីៗចុងក្រោយ ជាពិសេសការដែលនាយករដ្ឋមន្ត្រីកម្ពុជាកំពុងកាន់អំណាច អួតអំពីកម្ពុជាជានីតិរដ្ឋ ហើយ រដ្ឋាភិបាលបានចោទប្រកាន់ជនជាតិសៀម *ស៊ីវ៉ារ៉ាក់ ជុធិពង់* អាយុ៣១ឆ្នាំ ក្នុងបទចារកម្ម ប៉ះពាល់ដល់សន្តិសុខជាតិកម្ពុជា ដែលតុលាការសាលាដំបូងក្រុងភ្នំពេញក៏បានកាត់ទោសឱ្យជាប់

តទៅទំព័រទី៤ ម

## បណ្ឌិតអាមេរិកាំង ភីធី ម៉ាក់វែល: អង្គការសហប្រជាជាតិពុំមានជម្រើសណាល្អជាងដកខ្លួនពីតុលាការខ្មែរក្រហមដើម្បីកុំឱ្យខូចឈ្មោះ

ដោយ : យុទ្ធ ពន្យ

អ្នកសង្កេតការណ៍សញ្ជាតិអាមេរិកាំងម្នាក់ដែលជាសាស្ត្រាចារ្យបណ្ឌិតបង្រៀននៅសាកលវិទ្យាល័យមួយនៃសហរដ្ឋអាមេរិក បានអធិប្បាយថា ក្នុងករណីដែលរដ្ឋាភិបាលកម្ពុជានៃនាយករដ្ឋមន្ត្រី *ហ៊ុន សែន* ដែល

តទៅទំព័រទី៤ គ


លោក ជា ស៊ីម


លោក ហេង សំរិន

## ស្លាកលេខរថយន្តទំនើបៗ ខ.ម និង ន.ប របស់អ្នកធំមានព្រោងព្រាតវិញហើយ




លោក ហ៊ុន សែន នាយករដ្ឋមន្ត្រីខ្មែរ និងស្លាកលេខរថយន្ត ន.ប និង ខ.ម ពេលសមត្ថកិច្ចដោះចេញពីយានយន្តកន្លងមក

ដោយ : ចរិយា

រយៈពេល២សប្ដាហ៍នេះ នៅទីក្រុងភ្នំពេញ រថយន្តទំនើបៗ ដែលគេស្គាល់ថា ជារបស់មន្ត្រីយោធា មន្ត្រីនគរបាល ដូចជា រថយន្ត Lexus និងឡង់គ្រីស័រ នោះ មានខ្លះ ប្រើស្លាកលេខ ខ.ម និង ន.ប វិញហើយ ដែល

តទៅទំព័រទី២ ស

## FBI ដឹងថាខ្វះការសហការនៅក្នុងការស៊ើបអង្កេតការគប់គ្រាប់បែកឆ្នាំ១៩៩៧


លោក សម រង្ស៊ី គោរពវិញ្ញាណក្ខន្ធបាតុករដែលស្លាប់ដោយសារការគប់គ្រាប់បែក


សោកនាដកម្មក្រោយពីការគប់គ្រាប់បែកនៅមុខរដ្ឋសភាចាស់ថ្ងៃទី៣០មីនា១៩៩៧

រយៈពេលប៉ុន្មានថ្ងៃនេះសារព័ត៌មាន The Cambodia Daily ដែលកំពុងពេញនិយម នៅប្រទេសកម្ពុជា បានចុះផ្សាយអត្ថបទ ស្តីអំពីរបាយការណ៍ របស់ FBI ដែលលាតត្រដាង អំពីការវាយប្រហារ ដោយគ្រាប់បែកដៃចំនួន៤គ្រាប់ សំដៅលើក្រុមមនុស្សធ្វើបាតុកម្មអហិង្សាជាង ២០០នាក់ ដែលដឹកនាំ ដោយលោក*សម រង្ស៊ី* ដើម្បីទាមទារ

តទៅទំព័រទី២ ន

ក្រុមហ៊ុនសំណង់ ថៃ ឡាគី នាំចេញ នាំចូល

THAY-LAKY IMPORT EXPORT AND CONSTRUCTION Co.,Ltd

## ប្រុសទំនើងពីរនាក់បាញ់បោះក្នុងក្រុងភ្នំពេញ ដូចគ្នាតែមានសំណាងជាងស្រីទំនើងខែដារ៉ា


ជនដែលបាញ់បោះសេរី ហើយមិនមានទោស (រូប កាសែតដើមអម្ពិល)


ស្រីទំនើង ខែ តារា ដែលបាញ់បោះសេរីដូចគ្នា មានវាសនាជាប់គុក

ដោយ : រចនា

ជនដែលស្គាល់ អត្តសញ្ញាណពិតប្រាកដចំនួន២នាក់បានបាញ់បោះបង្កការភ័យខ្លាច នៅក្នុងទីក្រុងភ្នំពេញ កាលពីប៉ុន្មានថ្ងៃនេះ ដែលពួកគេបង្ហាញឫកពារជាប្រុសទំនើងដែរ ។ ប៉ុន្តែជនទំនើងទាំងពីរនេះ មានសំណាងល្អជាងស្រីទំនើង*ខែ ដារ៉ា* ហៅ *ហ៊្គិច* និងហៅ*កែវ រតនៈ* ដែលកំពុងជាប់ពន្ធនាគារព្រៃស ។

តទៅទំព័រទី២ ជ

ប្រសិនបើលោកអ្នកមានចំណាប់អារម្មណ៍

ផ្សព្វផ្សាយ ពាណិជ្ជកម្ម

លើទំព័រសារព័ត៌មានខ្មែរម្ចាស់ស្រុក

សូមទាក់ទងមកកាន់

ទូរស័ព្ទ : 017 360 678

ទូរសារ : 023 987 411

E-mail : kmsnews@gmail.com

www.kmsdaily.blogspot.com

## តំណាងរាស្ត្រគណបក្សសមរង្ស៊ីនឹងចុះទៅពិនិត្យកន្លែងបោះបង្គោលព្រំដែននៅថ្ងៃស្អែក

ដោយ : សីហា

បើទោះបីជា ស្ថានការណ៍នយោបាយនៅកម្ពុជាប៉ុន្មានថ្ងៃចុងក្រោយនេះត្រូវបានក្រុមអ្នកនយោបាយខ្លះព្យាយាមអោយមហាជនខ្មែរផ្តោតអារម្មណ៍ទៅលើបញ្ហាជម្លោះ ជាមួយសៀមជាពិសេស បញ្ហាកាត់ទោសចារកម្មសៀម ហើយត្រូវបាន ព្រះមហាក្សត្រខ្មែរប្រទានការលើកលែងទោសក៏ដោយ ក៏ថ្នាក់ដឹកនាំគណបក្សសមរង្ស៊ីរក្សាជំហររឹងមាំ អំពីការការពារ បូរណភាពទឹកដីដដែល គឺទាំងបញ្ហានៅតំបន់ព្រំដែន ជាមួយសៀម ក៏ដូចជាមួយយួន ។

នៅថ្ងៃទី១៤ ខែធ្នូ ២០០៩ ស្អែកនេះ គណៈប្រតិភូ របស់គណបក្សសម រង្ស៊ី ដែលក្នុងនោះ រួមមានអ្នកតំណាងរាស្ត្រផង បានចុះទៅពិនិត្យ កន្លែងបោះបង្គោលព្រំដែនជាមួយនឹងប្រទេសជិតខាង ។ នៅក្នុងដំណើរ ចុះទៅធ្វើការស៊ើបអង្កេតលើការបោះបង្គោលព្រំដែននេះ ក៏បាននាំយក សាររបស់លោក

តទៅទំព័រទី៣ ខ

*បរិយាយថ្ងៃនេះ*

## ហេតុអ្វីគេពន្យារពេល១៥ឆ្នាំ ក្នុងការធ្វើច្បាប់ប្រឆាំងអំពើពុករលួយ?

ដោយ : ហង្ស ធ្រាដ្ឋា

តាមការថ្លែងរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន នៅឯកិច្ចប្រជុំគណៈរដ្ឋមន្ត្រីកាលពីថ្ងៃសុក្រ ទី១១ ខែធ្នូ លើកឡើងនូវបញ្ហាអំពើពុករលួយនោះ វាពិតជាធ្វើឱ្យមានការចាប់អារម្មណ៍ ជាពិសេសត្រង់ការកត់សម្គាល់របស់នាយករដ្ឋមន្ត្រីខ្មែរ។ គឺការកត់សម្គាល់របស់គាត់ដែលប្រើពាក្យថា អំពើពុករលួយចាត់ទុកថា ជាឃាតកសម្លាប់រដ្ឋាភិបាល

តទៅទំព័រទី៤ ក

សារព័ត៌មាន "ខ្មែរម្ចាស់ស្រុក" ប្រចាំថ្ងៃ ទំព័រទី០២
Tel: 017 360 678 , E-mail : kmsnews@gmail.com

**តមកពីទំព័រទី១ ន**

អោយមានការកែទម្រង់ប្រព័ន្ធតុលាការនៅកម្ពុជា ។

នៅក្នុងការចេញផ្សាយរបស់ The Cambodia Daily កាលពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៩ម្សិលមិញនេះ គឺនិយាយអំពីការជួបការលំបាក របស់ FBI អំពីការរកកិច្ចសហការជាមួយអាជ្ញាធរកម្ពុជា ។ ខ្លឹមសារ នៃអត្ថបទនោះមានដូចតទៅ :

យោងតាមឯកសារ ដែលទើបប្រកាសជាចំហ បានអោយដឹងថា ក្នុងរយៈពេល៦សប្តាហ៍ ដែលពួកគេមានវត្តមាន នៅប្រទេសកម្ពុជា ដើម្បីស៊ើបអង្កេតការវាយប្រហារ ដោយគ្រាប់បែកដៃនៅឆ្នាំ១៩៩៧នោះភ្នាក់ងារមួយក្រុម ដែលមានគ្នា៣នាក់ របស់ការិយាល័យ ស៊ើបអង្កេតសហព័ន្ធអាមេរិក(FBI) បានឱ្យដឹងថា សហការីកម្ពុជារបស់ពួកគេ គ្មានឆន្ទៈនិងសូម្បីតែ វិធានការណាមួយ ដើម្បីបង្ហាញអត្តសញ្ញាណ ជនល្មើសក្នុងការវាយប្រហារលើការជួបជុំគ្នារបស់គណបក្សប្រឆាំង ។

ដោយធ្វើឡើង នៅក្នុងរយៈពេលប៉ុន្មានសប្តាហ៍ និងប៉ុន្មានថ្ងៃ មុនការតស៊ូអំណាច រវាងនាយករដ្ឋន្ត្រីទាំងពីរ( ហ៊ុនសែន និងសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ) របស់កម្ពុជាដែលត្រូវបានបញ្ចប់ នៅក្នុងការប្រយុទ្ធគ្នាដ៏ធំនៅតាមផ្លូវ ក្នុងរាជធានីនោះ ឯកសាររបស់ FBI ក៏បានកត់ត្រា អំពីភាពតានតឹង និងស្ថានភាព ដែលអាចប្រែប្រួលយ៉ាងខ្លាំង នៅក្នុងរដ្ឋាភិបាលកម្ពុជា ដែលបែកបាក់គ្នា និងភាពអាចកើតមានឡើង គ្រប់ទីកន្លែងនៃអំពើហិង្សា ដែលនៅទីបញ្ចប់ បានបណ្តាលឱ្យ FBI ដកខ្លួនចេញពីប្រទេសនេះ ។

នៅការថ្លែង ជាសាធារណៈលើកដំបូងរបស់លោក អំពីការស៊ើបអង្កេតនេះ លោក*ថូម៉ាស់ ទីកូលែតទី* ជាភ្នាក់ងារពិសេសដែលចូលនិវត្តន៍របស់ FBI និងជាភ្នាក់ងារស៊ើបអង្កេត ករណីនេះ ដែលត្រូវបានចាត់តាំងឱ្យដឹកនាំការស៊ើបអង្កេតនេះ បានអះអាងថា លោកត្រូវបានជូនដំណឹង ទាំងដោយ លោក*ខេន ណេិតខ្វីន* ជាឯកអគ្គរដ្ឋទូតអាមេរិក នៅពេលនោះ និងនគរបាលកម្ពុជាថា លោកត្រូវបានគេចុចឈ្មោះ សម្រាប់ការធ្វើឃាត ដោយ "*ក្រុមឃាតកស៊ីឈ្នួល*" ពីរក្រុម នៅទីក្រុងភ្នំពេញ ។

លោក *ខ្វីន* បានបដិសេធយ៉ាងខ្លាំងថា មិនបានបញ្ចេញពត៌មានបែបនេះទៅអោយភ្នាក់ងារ *ទីកូលែតទី* ទេ។ ក្រសួងមហាផ្ទៃ មិនបានឆ្លើយតប នឹងសំណើរ ជាលាយលក្ខណ៍អក្សរសុំធ្វើការសម្ភាសន៍ សំរាប់អត្ថបទនេះទេ ។

ឯកសារដែលត្រូវបានគេប្រកាសជាចំហទាំងនេះ ក៏បង្ហាញដែរថា យ៉ាងហោចណាស់មន្ត្រី FBI ម្នាក់ ដែលទទួលខុសត្រូវចំពោះការបង្កើត ទំនាក់ទំនងសហប្រតិបត្តិការជាមួយអាជ្ញាធរខ្មែរដឹងថា ការស៊ើបអង្កេតការវាយប្រហារ ដោយគ្រាប់បែកដៃនេះមានបញ្ហា ពីព្រោះវាអាចបង្ហាញ ពីការជាប់ពាក់ព័ន្ធរបស់មនុស្ស នៅ គណបក្សប្រជាជនកម្ពុជា នៅពេលដែល FBI ព្យាយាមសហការជាមួយគណបក្សនេះ ។

ការវាយប្រហារ បានកើតឡើងនៅម៉ោង៨:២៥នាទី នៅថ្ងៃទី៣០ មីនា ១៩៩៧ ដែលនៅពេលនោះជនល្មើសដែលគេមិនស្គាល់មុខបានគប់គ្រាប់បែកដៃM-33 ដែលផលិតនៅអាមេរិកចំនួន៤គ្រាប់ចូលទៅក្នុងការជួបជុំគ្នារបស់គណបក្សជាតិខ្មែរ ដែលដឹកនាំ ដោយលោក *សម រង្ស៊ី* ប្រធានគណបក្ស នៅក្នុងសួនច្បារនៅទល់មុខអតីតមន្ទីររដ្ឋសភាដែលស្ថិតតាមបណ្តោយមហាវិថីសុធារស ។

យ៉ាងហោចណាស់ ក៏បាតុករអហិង្សា១៦នាក់បានស្លាប់ និងជាង ១០០នាក់ទៀត បានរងរបួស ។

ទោះជា ក្រុមមន្ត្រីនគរបាលមួយក្រុមតូច ហាក់ដូចជាដកខ្លួនចេញ មុនការវាយប្រហារនេះបន្តិចក៏ដោយ ក៏ទាហានកងយោធពលខេមរភូមិន្ទ ត្រៀមប្រយុទ្ធមួយក្រុមដែលFBI បានបង្ហាញអត្តសញ្ញាណថា ជាអង្គរក្សផ្ទាល់របស់លោក*ហ៊ុន សែន* នាយករដ្ឋមន្ត្រីទី២ នៅពេលនោះ ត្រូវបានដាក់ពង្រាយនៅពីរក្រោយការជួបជុំគ្នាដែលនៅតាមផ្លូវលេខ៧ ។

ខុសពីការស៊ើបអង្កេត ការបំផ្ទុះគ្រាប់បែក នៅ Khobar Towers ឆ្នាំ១៩៩៦នៅប្រទេសសាអូឌីអារ៉ាប៊ីនិងការបំផ្ទុះគ្រាប់បែកឆ្នាំ១៩៩៨ នៅឯស្ថានទូតអាមេរិក ក្នុងប្រទេសអាហ្វ្រិក ដែលនៅក្នុងនោះ ជនជាតិអាមេរិក រាប់សិបនាក់ បានស្លាប់នោះ ។ ការស៊ើបអង្កេតរបស់ FBI នៅក្នុងការវាយប្រហារឆ្នាំ ១៩៩៧ នៅក្នុងប្រទេសកម្ពុជា ជាប់ពាក់ព័ន្ធ នឹងជនជាតិអាមេរិកដែលរងរបួសតែម្នាក់គត់ ។

ដូចដែលពួកគេបានធ្វើ លើរឿងក្តីធ្វើឃាត ដែលមិនទាន់ដោះស្រាយជាច្រើន លើសកម្មជននយោបាយ មេដឹកនាំសហជីព អ្នកកាសែត និងសិល្បករល្បីៗនោះ នគរបាលកម្ពុជាបានបង្កើតគណៈកម្មការស៊ើបអង្កេតមួយភ្លាមៗដែលមានមន្ត្រីនគរបាល មកពីគណបក្សហ្វ៊ុនស៊ិនប៉ិច និងគណបក្សប្រជាជន ។

ការវាយតម្លៃតំបូង ពីមន្ត្រីស្ថានទូតអាមេរិកនិងមន្ត្រី FBI នៅពេលដែល ការស៊ើបអង្កេតបានចាប់ផ្តើម នៅពាក់កណ្តាលខែមេសា ១៩៩៧គឺថា សមាសភាគ មកពីគណបក្សប្រជាជនកម្ពុជា ជំទាស់ទៅនឹងការស៊ើបអង្កេតឯករាជ្យណាមួយនេះបើយោងតាមឯកសាររបស់FBI ។

លោក *ទីកូលែតទី* ក៏ចាប់ផ្តើមមានជំនឿថាគណៈកម្មការស៊ើបអង្កេតនេះដែលត្រូវ បានដឹកនាំជាផ្លូវការ ដោយលោក *យ៉េង ម៉ារ៉ាឌី* អគ្គស្នងការនគរបាលជាតិ មកពីគណបក្សហ្វ៊ុនស៊ិនប៉ិច និងលោក*ហុក ឡុងឌី* ឧត្តមសេនីយ៍នគរបាល មកពីគណបក្សប្រជាជនកម្ពុជាដែលនៅពេលនោះ ជាអគ្គស្នងការនគរបាលជាតិនោះបានផ្លាស់ប្តូរភស្តុតាង សម្រាប់ការធ្វើបទបង្ហាញដល់ FBI ។

ក្នុងរង្វង់២៤ម៉ោង នៃការវាយប្រហារលោក*រ៉ាលហ្វ ហតថុន* អនុព័ន្ធផ្នែកច្បាប់ របស់ FBI នៅស្ថានទូតអាមេរិកប្រចាំ នៅទីក្រុងបាងកក បាននិយាយទូរស័ព្ទ ជាមួយក្រុមហូណូលូលូ របស់ FBI នៅរដ្ឋហាវ៉ៃ ជាទីដែលភ្នាក់ងារទទួលបន្ទុកពិសេសគឺលោក *ចន ស៊ីមែន* ។ មួយថ្ងៃបន្ទាប់មក លោក *ហតថុន* បានផ្ញើតាមទូរសារ នូវឯកសារថតចម្លង របស់ស្ថានទូតអាមេរិក ដែលពណ៌នា អំពីការវាយប្រហារនេះ ទាំងនៅទីក្រុងហូណូលូលូ និងការិយាល័យ FBI នៅទីស្នាក់ការកណ្តាល ក្នុងទីក្រុងវ៉ាស៊ីនតោន ដែលនៅពេលនោះ គេស្គាល់ថា ជាក្រុមសន្តិសុខជាតិ ។

នៅក្នុងលិខិតអមនោះលោក *ហតថុន* បានថ្លែងដោយច្រឡំថា "*ពលរដ្ឋអាមេរិកម្នាក់ បានស្លាប់* "។

លោក*ហតថុន* បានសរសេរថា "*ទាំងទ្រព្យសម្បត្តិ និងជនជាតិអាមេរិកមិនទំនងជាគោលដៅនៃការវាយប្រហារទេ*" ។

លោក*រុន អាប់នី* នាយកប្រចាំ នៅប្រទេសកម្ពុជា នៃវិទ្យាស្ថាន សាធារណរដ្ឋអន្តរជាតិអាមេរិក (IRI) ដែលតាមពិត បានរួចជីវិតពីរបួសអំបែងគ្រាប់ត្រូវចំត្រគាក នឹងត្រូវបានបញ្ជូន ទៅព្យាបាល នៅមន្ទីរពេទ្យ Mount Elizabeth ក្នុងប្រទេសសិង្ហបុរីនោះ "*បានរងគ្រោះដោយចៃដន្យទេ*" ។

នៅថ្ងៃទី២ ខែមេសា FBI បានបើកការស៊ើបអង្កេត ជាផ្លូវការ ។ ពីរថ្ងៃក្រោយមកលោក *ទីកូលែតទី* ដែលជា ភ្នាក់ងារពិសេស បានសម្ភាសន៍ លោក *អាប់នី*នៅឯគ្រែរបស់លោកក្នុងមន្ទីរពេទ្យជាទីដែលលោកបានរៀបរាប់ថាបានចូលទៅចាប់ដៃជាមួយមនុស្សម្នាក់ នៅពេលដួលទៅលើដីដោយសារការផ្ទុះលើកទីមួយ ។ តាមពិតលោក *អាប់នី* "*បានរងរបួសដោយសារលោកស្ថិតនៅជិតគោលដៅធ្វើឃាត*" នេះបើយោងតាម ការរៀបរាប់ ដែលសរសេរនៅក្នុងឯកសារ ដែលមានចំណងជើងថា "*ព័ត៌មានរឿងក្តី*"របស់ FBI ជាឯកសារទីមួយ នៅក្នុងសំណុំរឿងនេះ ។

នៅថ្ងៃសម្ភាសន៍នោះ ក្រុមមេធាវី នៅផ្នែកភេរវកម្ម និងឧក្រិដ្ឋកម្មហិង្សានៃក្រសួងយុត្តិធម៌អាមេរិក នៅក្នុងទីក្រុងវ៉ាស៊ីនតោន បានបញ្ចេញយោបល់មួយថាដោយសារការរងរបួសចំពោះលោក *អាប់នី* FBI មានយុត្តាធិការ ស៊ើបអង្កេតតាមច្បាប់ប្រឆាំងភេរវកម្ម ។ ៥ថ្ងៃក្រោយមកនៅថ្ងៃទី៩ខែមេសាស្ថានទូតអាមេរិក បានទទួលសំណើជាផ្លូវការ ពីរដ្ឋាភិបាលខ្មែរសុំឱ្យ FBI ផ្តល់វិចិត្រករដើម្បីគូរគំនូរព្រាងរបស់ជនល្មើស ។

អំឡុងពេលស៊ើបអង្កេត នៅក្នុងទីក្រុងភ្នំពេញនោះ របាយការណ៍ និងសេចក្តីសង្ខេបពីការស៊ើបអង្កេត ត្រូវបានសរសេរក្នុងទូរលេខដាក់កំណត់សម្គាល់ថា "*អាទិភាព*" និងបញ្ជូនតាមរយៈក្រុងបាងកក ទៅការិយាល័យនៅក្នុងក្រុងហូណូលូលូនិងបញ្ជូន ទៅក្រុមសន្តិសុខជាតិ នៅក្នុងទីក្រុងវ៉ាស៊ីនតោន ។

**"នៅមានត"**

**តមកពីទំព័រទី១ ៩**

បុរសទំនើង ទាំង២រូប ដែលម្នាក់ ជាមន្ត្រីយោធា និងម្នាក់ទៀត ជាអ្នកមានទ្រព្យសម្បត្តិនោះត្រូវបានសារព័ត៌មានដែលមាននិន្នាការ គាំទ្រនយោបាយរដ្ឋាភិបាលបានលាតត្រដាងនៅទំព័រ ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៩ ដូចគ្នា ប៉ុន្តែកន្លែងដែលពួកគេបាញ់បោះនោះ បានប្រព្រឹត្តទៅខុសគ្នា គឺករណីមួយ បណ្តាលមកពីស្រវឹងស្រា និងករណីមួយទៀត បណ្តាលមកពី អ្នកជិតខាងងើបពីព្រលឹម ហាត់ប្រាណដើម្បីសុខភាពបង្កការ រំខានដំណេករបស់ខ្លួននោះ ។

ជនល្មើសទាំងពីររូបនេះ មិនត្រូវបានធ្លាក់ចូល ក្នុងសំណាញ់ច្បាប់ ឬសមត្ថកិច្ច អនុវត្តតាមបទបញ្ជារបស់លោក*ហ៊ុន សែន* ទេដោយគ្រាន់តែអាជ្ញាធរមូលដ្ឋានសួរនាំបន្តិចបន្តួច ក៏ដោះលែង ឱ្យមានសេរីភាពវិញ បើទោះបីជា អ្នកព្យាយាម ចាប់ខ្លួននោះ បានធ្វើឡើង ដោយលំបាកយ៉ាងណាក៏ដោយ ។

កាសែតកម្ពុជាថ្មី ដែលសព្វថ្ងៃ ជារបស់លោកស្រី*ហ៊ុន ម៉ាណា* កូនស្រីច្បង លោកនាយករដ្ឋមន្ត្រី*ហ៊ុន សែន* បានលាតត្រដាង នៅលើទំព័រប្រចាំថ្ងៃកាលពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៩ថា លោក*ម៉ាត់ សាម៉ុីន*អាយុ៤០ឆ្នាំ ជាអង្គរក្សលោកធំ ហើយប្រើកាំភ្លើងម៉ាកឡុកបាញ់ពី៤ ទៅ៥គ្រាប់ ក្នុងខណ្ឌឫស្សីកែវ រាជធានីភ្នំពេញបណ្តាលឱ្យមានការភ័យខ្លាចដល់ប្រជាពលរដ្ឋ ។

កម្ពុជាថ្មី បានពណ៌នាដំណើររឿងថាវរសេនីយទោ*ម៉ាត់ សាម៉ុីន* ដែលពាក់ស័ក្តិពេញ នៅពីលើស្មា ដែលគេដឹងថា ជាកងអង្គរក្ស លោកធំនោះ ត្រូវបានកម្លាំងសមត្ថកិច្ចចម្រុះ ប៉ូលិសប៉េអឹម ខណ្ឌឫស្សីកែវ ឡោមព័ទ្ធចាប់ខ្លួន បញ្ជូនមកទីបញ្ជាការកងរាជអាវុធហត្ថ រាជធានីភ្នំពេញ បន្ទាប់ពីយោធារូបនេះផ្ទុះអាវុធពី៤ ទៅ៥គ្រាប់ បានធ្វើឱ្យមានការភ្ញាក់ផ្អើល ដល់ប្រជាពលរដ្ឋ ដោយសារតែស្រវឹងស្រា កាលពីម៉ោង១០ យប់ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៩នៅភូមិ ខ១សង្កាត់ច្រាំងចំរេះទី២ ខណ្ឌឫស្សីកែវរាជធានីភ្នំពេញ។

សេចក្តីរាយការណ៍ បានឱ្យដឹងថា ករណីផ្ទុះអាវុធនេះ មិនបណ្តាលឱ្យ ត្រូវនរណាម្នាក់ទេ, ហើយមូលហេតុ នៃការផ្ទុះអាវុធទាំងកណ្តាលយប់នោះ មកពីឈ្មោះ*ម៉ាត់ សាម៉ុីន* ស្រវឹងស្រាយ ហើយទាស់សម្តីគ្នាតិចតួចជាមួយបងប្អូន ។ បន្ទាប់ពីមានហេតុការណ៍ ផ្ទុះអាវុធនេះកើតឡើង សមត្ថកិច្ចចម្រុះបានចុះទៅចាប់ខ្លួន ខ្មាន់កាំភ្លើងរូបនោះភ្លាមៗ បញ្ជូនមកទីបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញតាមបទបញ្ជារបស់លោក ឧត្តមសេនីយ៍ មេបញ្ជាការ កងរាជអាវុធហត្ថ រាជធានីភ្នំពេញ គឺទាំងមនុស្ស ទាំងកាំភ្លើង ។

ក្នុងរឿងរ៉ាវនេះ បើតាមប្រភព ដោយឡែកមួយទៀត ពីមន្ត្រីសាលាខណ្ឌឫស្សីកែវ បានបង្ហើបថា ខ្មាន់កាំភ្លើងនោះត្រូវបានគេដោះលែង ឱ្យមានសេរីភាពវិញហើយ បន្ទាប់ពីធ្វើការផ្ទុះអាវុធ មិនបានប៉ុន្មានម៉ោងផង ដោយសារតែមានមេកើយនៅកងអង្គរក្ស មកធានាយកចេញទៅយ៉ាងស្ងាត់ស្ងៀមហើយ ព័ត៌មាននេះ ក៏ត្រូវបានគេលាក់បាំងបំផុត ។

ចំពោះកាសែត ដើមអំពិល ដែលបានចុះផ្សាយនៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៩ដែរនោះ បានសរសេរថា ស្នូគ្រាប់កាំភ្លើង ២ គ្រាប់ បានបង្ហោះឡើងទៅលើ ដែលគេដឹងថាចេញភូមិគ្រឹះអ្នកមានលុយ និងអ្នកមានអំណាចម្នាក់ ធ្វើឱ្យមានការភ្ញាក់ផ្អើល ដល់ប្រជាពលរដ្ឋ និងសមត្ថកិច្ចនៅមូលដ្ឋាន ហើយអាជ្ញាធរក៏ចុះទៅធ្វើការសួរនាំ ដើម្បីចង់ដឹងមូលហេតុ នៃការផ្ទុះអាវុធខាងលើនេះ ។

ករណីបាញ់បោះ ដោយសេរីដែលបង្កឡើង ដោយជនល្មើសអាងខ្លួនមានប្រាក់ និងអំណាចនេះ បានកើតមានឡើងកាលពីព្រឹកព្រលឹមម៉ោង៥និង៥០នាទី ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩ ស្ថិតនៅចំណុចផ្ទះលេខ H-27 ផ្លូវបេតុង លេខ៥៧៩ ក្នុងបូរីសុភមង្គលសង្កាត់ជ្រោយចង្វារខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

ទាក់ទិន នឹងករណីបាញ់បោះបណ្តាលឱ្យ មានការភ្ញាក់ផ្អើលដល់ប្រជាពលរដ្ឋ និងអ្នកមានទីលំនៅក្បែរ កន្លែងកើតហេតុខាងលើនេះដោយសារបុរសជាជនល្មើស បានខឹងសម្បារ នឹងប្រជាពលរដ្ឋ ដែលងើបហាត់ប្រាណ នៅតាមដងផ្លូវខាងលើ ធ្វើឱ្យរំខាន ដល់ការដេករបស់ខ្លួន ក៏ដកកាំភ្លើង បាញ់ឡើងលើចំនួន២គ្រាប់តែម្តង ។ នៅបន្ទាប់ពីការផ្ទុះអាវុធ រួចមកក៏

**តទៅទំព័រទី៣ ៩**

**តមកពីទំព័រទី១ ៨**

ប៉ូលិសចរាចរធ្លាប់ឈរប្រមាញ់តាមដងផ្លូវនោះ ក៏មិនហ៊ានធ្វើអន្តរាគមន៍ ឃាត់រថយន្ត ទាំងនោះដែរ ។

បើយោងតាមការអោយដឹងរបស់គេហទំព័រ ក្នុងស្រុកមួយក៏បានបង្ហាញអត្តសញ្ញាណ រថយន្តទំនើប ដែលប្រើស្លាកលេខ ខ.ម និង ន.ប នេះផងដែរ ។

បើសិនមានការគយគន់ និងយកចិត្តទុកដាក់នោះគេសង្កេតឃើញ រថយន្ត ប្រើស្លាកលេខ ខ.ម និងន.ប មិនសូវចន្លោះថ្ងៃទេ ដែលធ្វើដំណើរឆ្លងកាត់នៅលើមហាវិថីនានា ក្នុងទីក្រុងភ្នំពេញ, ហើយរថយន្តខ្លះ ដែលធ្វើចរាចរ លើដងផ្លូវ ម៉ៅសេទុង សំដៅទៅទួលគោក ដែលជាតំបន់ ដែលពោរពេញ ដោយភូមិគ្រឹះធំៗ របស់មេទ័ព មន្ត្រីប៉ូលិស និងមន្ត្រីរាជរដ្ឋាភិបាលនោះ ។

មានពេលខ្លះ គេបានសង្កេតឃើញរថយន្តកាមរីឆ្លាម និងខ្លះកូរ៉ូឡាចង្កូតស្តាំ ហើយខ្លះទៀតជារថយន្តLexus និងឡង់គ្រីស័រតែម្តង គឺអ្នកបើកបរនោះ ខ្លះមានឯកសណ្ឋានស៊ីវិល និងខ្លះមានឯកសណ្ឋាន ជាប៉ូលិស ឬយោធា ។

លោក*ហ៊ុន សែន* បានថ្លែងនៅពេលថ្មីៗនេះដោយបញ្ជាឱ្យអនុវត្តន៏ បទបញ្ជារបស់លោក ឱ្យបានម៉ឹងម៉ាត់ ។ ប៉ុន្តែគេមិនដឹងថា តើបទបញ្ជារបស់លោក *ហ៊ុន សែន* នោះ សាបរលាបដល់កម្រិតណាទេ ដែលធ្វើឱ្យជនឱកាសនិយមខ្លះ ឆ្លៀតប្រើស្លាកលេខខ.ម និង ន.បព្រោងព្រាត នៅក្នុងទីក្រុងភ្នំពេញទៅហើយនោះ ។

មិនត្រឹមតែ មានអ្នកហ៊ានប្រើស្លាកលេខ ន.ប និង ខ.ម នោះទេ សូម្បីតែក្រុមជនទំនើងខ្លះ ក៏បានប្រើប្រាស់អាវុធបាញ់បោះ ដោយមិនខ្លាចច្បាប់ និងបទបញ្ជារបស់លោក*ហ៊ុន សែន* បន្តិចឡើយ ដូចជាកាលពីថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០០៩ កន្លងទៅនេះ គឺមានជនប្រមឹកម្នាក់ ជាមន្ត្រីយោធា នៃកងអង្គរក្សអ្នកមានអំណាចនិងម្នាក់ទៀតអាងប្រាក់និងអំណាចនោះបានបាញ់កាំភ្លើង បណ្តាលឱ្យសមត្ថកិច្ចចាប់ខ្លួននិងកោះហៅទៅសួរនាំទៀតផង ។ ប៉ុន្តែអ្នកដែលប្រព្រឹត្តបទល្មើស ទាំងពីររូបនេះមិនត្រូវបានច្បាប់ផ្តន្ទាទោសទេ គឺកំពុងរស់នៅ លើលំនៃសេរីភាពនៅឡើយ ។ បញ្ហានេះបានធ្វើឱ្យមានការរិះគន់ថា តើបទបញ្ជារបស់ លោក*ហ៊ុន សែន* អស់ សុពលភាពហើយឬនៅ ?

ជាមួននឹងការញ៉ាំញី ទៅលើបទបញ្ជារបស់លោកនាយករដ្ឋមន្ត្រី*ហ៊ុន សែន* នេះ ក្រុមក្មេងស្ទាវ ក៏បានបង្ហោះម៉ូតូ នៅតាមដងផ្លូវ ទៅតាមទម្លាប់ របស់ពួកគេម្តងៗដែរហើយនៅពេលដែល ក្រុមក្មេងស្ទាវទាំងនោះមិនឃើញសមត្ថកិច្ច ។ ក្រុមក្មេងស្ទាវបង្ហោះម៉ូតូទាំងនោះគឺមានពេលខ្លះ បានធ្វើឡើងនៅក្បែរប៉ុស្តិ៍នគរបាល សង្កាត់ទន្លេបាសាក់ និងនៅមុំសួនច្បារ ប្រមុខរដ្ឋាភិបាល*ហ៊ុន សែន* និងសួនច្បារលោក*ជា ស៊ីម* នៅពីសណ្ឋាគារ កាំបូឌីយ៉ាណា តែម្តង ។

ដោយសារតែ សមត្ថកិច្ចមិនមានវិធានការ តាមបទបញ្ជាលោក*ហ៊ុន សែន* ឱ្យបានម៉ឺងម៉ាត់ ឬក៏លោក*ហ៊ុន សែន* កំពុងជាប់រវល់ ធ្វើសង្គ្រាមពាក្យសម្តី ជាមួយមេដឹកនាំសៀមឬយ៉ាងណាទេ បានជាក្រុមក្មេងទំនើង បុរសទំនើង រំលោភទៅលើបទបញ្ជា របស់លោក*ហ៊ុន សែន* ផ្ទួនៗបែបនេះ ជាពិសេសរថយន្តប្រើស្លាកលេខ ខ.ម និង ន.ប មានព្រោងព្រាត នៅក្នុងទីក្រុងភ្នំពេញវិញហើយ ៕

**តមកពីទំព័រទី១ ខ**

*សមរង្ស៊ី* ទៅចែកជូនប្រជាពលរដ្ឋនៅតាមព្រំដែនផងដែរដែលសារនោះគឺធ្វើការប្រៀបធៀបរវាងប្រទេសយួន និងសៀម ដែលធ្វើអោយ គ្រោះថ្នាក់ជាតិខ្មែរ ។ សារនោះក៏បានត្រូវបានថ្នាក់ដឹកនាំគណបក្សសម រង្ស៊ី បោះពុម្ពរាប់ម៉ឺនសន្លឹកចែកជូនដល់ប្រជាពលរដ្ឋ ខ្មែរទូទាំងប្រទេសផងដែរ ។

ខ្លឹមសារនៃសារមានដូចខាងក្រោមនេះ :

លោក នាយករដ្ឋមន្ត្រី *ហ៊ុន សែន* កំពុងលែងល្បែង ប្រកបដោយគ្រោះថ្នាក់ចំពោះប្រទេសយើង ។ គាត់ហាក់ដូចជាបាត់បង់ស្មារតី ក្នុងការគ្រប់គ្រង ទំនាក់ទំនង របស់ប្រទេសកម្ពុជាជាមួយប្រទេសជិតខាង ។

នយោបាយការបរទេសរបស់រដ្ឋាភិបាលយើងបច្ចុប្បន្ន មានការលំអៀងទាំងស្រុងនៅពេលដែលរាជរដ្ឋាភិបាល ត្រូវការពារបូរណភាពទឹកដី នៃប្រទេសកម្ពុជា ។ លោកនាយករដ្ឋមន្ត្រីអះអាងថា គ្រោះថ្នាក់នៃការបាត់បង់ទឹកដីមួយផ្នែក របស់ប្រទេសកម្ពុជា អាចកើតមានឡើងនៅតាមព្រំដែនយើង ជាមួយប្រទេសថៃ ។ ប៉ុន្តែគាត់ភ្លេចនិយាយថា គ្រោះថ្នាក់នេះបាននិងកំពុងតែកើតមាន យ៉ាងធ្ងន់ធ្ងររួចទៅហើយ នៅតាមព្រំដែនភាគខាងកើត ជាមួយប្រទេសវៀតណាម ។

យើងគួរធ្វើការប្រៀបធៀបដូចតទៅ :

-ប្រទេសថៃ ទើបតែ នៅពេលថ្មីៗនេះ បានចាប់ផ្តើមបង្ករឿងឱ្យយើងនូវភាពអយុត្តិធម៌ ដោយសើរើ អធិបតេយ្យភាពប្រទេសកម្ពុជា នូវតំបន់ជុំវិញប្រាសាទព្រះវិហារ ក្នុងខេត្តព្រះវិហារ លើផ្ទៃដីទំហំមិនដល់៥គីឡូម៉ែត្រក្រឡាផង ។

-ប្រទេសវៀតណាម ក្នុងរយៈពេលជាង៣០ឆ្នាំកន្លងមកហើយ បានរំលោភយកដីខ្មែររាប់ពាន់គីឡូម៉ែត្រក្រឡា នៅខេត្តកែប កំពតតាកែវ កណ្តាល ព្រៃវែង ស្វាយរៀង កំពង់ចាម ក្រចេះ មណ្ឌលគីរី រតនគីរី ។ នេះជាដំណើរការ ដ៏ឈឺចាប់មួយ ដែលកំពុងតែបន្តទៅមុខ ដែលលោក*ហ៊ុន សែន* មិនចង់ឱ្យយើងឃើញទេ ។ ប៉ុន្តែយើងមិនអាចឈរឱបដៃ នៅស្ងៀមបានទេចំពោះការបង្ហូរទឹកភ្នែក និងសម្រែកឈឺចាប់ របស់ប្រជាកសិករខ្មែររាប់ម៉ឺននាក់ដែលកំពុងបាត់បង់ដីស្រែ និងដីចំការ របស់ពួកគាត់ ដោយសារតែប្រទេសវៀតណាម ត្របាក់យក ។ ហេតុការបែបនេះ ខ្ញុំបានឃើញជាសាក្សីក្នុងពេលថ្មីៗនេះ នៅខេត្តស្វាយរៀង ។

យើងមិនមាន ជនអន្តោប្រវេសន៍ថៃនៅប្រទេសកម្ពុជា ។ តែមានការហូរចូលជាច្រើន នូវជនអន្តោប្រវេសន៍យួន ដែលជាសញ្ញាមួយទៀត នៃយុទ្ធសាស្ត្រពង្រីកទឹកដី ដែលប្រទេសវៀតណាម កំពុងតែអនុវត្ត ដោយមានការគាំទ្រ និងការចុះញ៉ម ពីសំណាក់រដ្ឋាភិបាលលោក*ហ៊ុន សែន* ។

ព្រះវរៈរាជបិតា ព្រះករុណា សម្តេចព្រះ*នរោត្តម សីហនុ*ព្រះអង្គបានសំដែង ពីព្រះទ័យទុក្ខកង្វល់របស់ព្រះអង្គចំពោះស្ថានភាពនៅតាមបណ្តាខេត្ត នៃប្រទេសកម្ពុជា ដែលស្ថិតនៅតាមព្រំដែន ជាមួយប្រទេសវៀតណាម ។ ខ្ញុំបានទូលថ្វាយព្រះអង្គកាលពីដើមខែនេះ អំពីការបាត់បង់ដីស្រែ របស់ប្រជាកសិករខ្មែរ ដោយសារការរុករានទន្ទ្រានកាន់កាប់ របស់អាជ្ញាធរវៀតណាមនៅខេត្តស្វាយរៀង ។ ព្រះអង្គបានយកព្រះទ័យ ទុកដាក់ ចំពោះរបាយការណ៍ខ្ញុំនេះ ហើយព្រះអង្គ បានផ្ញើព្រះរាជសារមួយច្បាប់ ទៅជូនលោកនាយករដ្ឋមន្ត្រី*ហ៊ុនសែន*ដោយស្នើអោយពិនិត្យព័ត៌មាន និងភស្តុតាង ដែលខ្ញុំ បានលាតត្រដាងទាក់ទងនឹងបញ្ហានេះ ។ ជាចម្លើយដ៏ព្រហើន ចំពោះព្រះវរៈរាជបិតា រដ្ឋាភិបាល លោក*ហ៊ុន សែន* និងរដ្ឋសភា ប្រថាប់ត្រាសព្វថ្ងៃ បានដកអភ័យឯកសភាររបស់ខ្ញុំដោយរំលោភគោលការណ៍ប្រជាធិបតេយ្យ ដើម្បីផ្តន្ទាទោសខ្ញុំ ពីព្រោះខ្ញុំហ៊ានលើកយកមកលាតត្រដាង នូវបញ្ហាជាតិដែលធ្វើឱ្យនាយករដ្ឋមន្ត្រីមានការខ្មាសអៀន ។

លោក*ហ៊ុន សែន* កំពុងប្រើល្បិចចាស់គំរិលមួយដើម្បីបង្វែរអារម្មណ៍ប្រជារាស្ត្រខ្មែរពីគ្រោះថ្នាក់ពិតប្រាកដ ដែលបាននិងកំពុងកើតចេញ ពីតំបន់ព្រំដែនភាគខាងកើត ជាមួយប្រទេសវៀតណាម ។ ក្នុងបំណងបង្វែរអារម្មណ៍ប្រជារាស្ត្រខ្មែរ ពីការឈ្លានពាន របស់ប្រទេសវៀតណាម លោក*ហ៊ុន សែន* បានធ្វើអោយមានភាពតានតឹង កាន់តែខ្លាំងឡើងៗ ក្នុងទំនាក់ទំនងជាមួយប្រទេសថៃ ដើម្បីបង្កឱ្យមានការចាប់អារម្មណ៍តែចំពោះព្រំដែនភាគខាងលិចជាមួយប្រទេសថៃ ។

លោក*ហ៊ុន សែន* ធ្វើយ៉ាងដូច្នេះ ដើម្បីសំរេចគោលបំណងដូចតទៅ :

*សម្រាប់ខ្លួនគាត់ផ្ទាល់ និងបក្ខពួកគាត់នៅកម្ពុជា*

-ទទួលបានការគាំទ្រ ជាបន្តពីប្រទេសវៀតណាមយ៉ាងខ្លាំង ដើម្បីរក្សាអំណាច ហើយទប់ទល់ទៅនឹងនិន្នាការ ប្រជាធិបតេយ្យទាំងអស់ ។

-ដុតអោយមានកំហឹង ជាតិនិយមប្រឆាំង នឹងប្រទេសថៃ ដើម្បីជួយគាត់ ធ្វើអោយប្រជារាស្ត្រខ្មែរបំភ្លេចអំពីការលំបាកខាងផ្នែកជីវភាព ដោយសារតែវិបត្តិសេដ្ឋកិច្ច អំពើពុករលួយ និងអសមត្ថភាព របស់រដ្ឋាភិបាល ។

*សម្រាប់ប្រទេសវៀតណាម ដែលជាអ្នកការពារគាត់*

-បង្កើនពាណិជ្ជកម្ម ជាមួយប្រទេសកម្ពុជា និងបង្កើនឥទ្ធិពលសេដ្ឋកិច្ចលើប្រទេសកម្ពុជា

-បង្កើនការត្រួតត្រាមកលើសេដ្ឋកិច្ច របស់ប្រទេសកម្ពុជាតាមរយៈការបង្កើន វិនិយោគពីប្រទេសវៀតណាមដែលក្រុមហ៊ុនរបស់គេមានបុព្វសិទ្ធិលើសគេឯងនៅប្រទេសយើង នៅពេលដែលក្រុមហ៊ុន ពីប្រទេសថៃកំពុងចុះថយ និងដកខ្លួនថយដោយសារភាពតានតឹង រវាងប្រទេសកម្ពុជា និងប្រទេសថៃនាពេលបច្ចុប្បន្ននេះ ។ ស្ថានភាពបច្ចុប្បន្នធ្វើអោយយើងនឹកឃើញដល់កុប្បកម្ម ប្រឆាំងថៃនៅភ្នំពេញ ដែលរៀបចំឡើងដោយក្រុមអន្ធពាល បំរើលោក*ហ៊ុន សែន* កាលពីខែមករា ឆ្នាំ២០០៣ ។

មើលតាមទស្សនៈវិស័យ ប្រវត្តិសាស្ត្រ និងភូមិសាស្ត្រនយោបាយ ប្រទេសថៃគឺជាគូប្រកួតដ៏សំខាន់របស់ប្រទេសវៀតណាម នៅជ្រោយឥណ្ឌូចិន ។ ដូច្នេះការធ្វើអោយប្រទេសថៃចុះទន់ខ្សោយ គឺជាការធ្វើឱ្យប្រទេសវៀតណាម ទទួលបានផលប្រយោជន៍ក្នុងរយៈពេលយូរអង្វែងនាពេលខាងមុខ ។ ការវាតទីរបស់វៀតណាមនៅថ្ងៃណាមួយអាចទៅហួសឆ្ងាយជាងប្រទេសកម្ពុជា និងប្រទេសឡាវ ទៅទៀត ពីព្រោះប្រទេសទាំងពីរនេះ ស្ថិតក្រោមការត្រួតត្រារបស់ប្រទេសវៀតណាម រួចស្រេចហើយនៅពេលនេះ ទោះច្រើនក្តីតិចក្តី ។ ដើម្បីធ្វើអោយប្រទេសថៃចុះទន់ខ្សោយ គ្មានអ្វី ដែលមានប្រសិទ្ធភាពជាងការធ្វើឱ្យប្រជាជនថៃបែកបាក់គ្នាកាន់តែខ្លាំងហើយគាំទ្រក្រុមមួយអោយប្រយុទ្ធប្រឆាំងក្រុមមួយទៀតនោះទេ ។ លោក*ហ៊ុន សែន* ជាឧបករណ៍ប្រើប្រាស់ ដ៏មានប្រសិទ្ធភាព ដែលប្រទេសទីពាក់កំពុងយកទៅប្រើក្នុងល្បែងដែលពោរពេញដោយល្បិចកលសម្រាប់អនុវត្តផែនការ ដ៏ខ្មៅងងឹតមួយ ។ អ្នកណាក៏ដោយដែលយកខ្លួន ទៅផ្សារភ្ជាប់ជាមួយលោក*ហ៊ុន សែន* ដើម្បីគាំទ្រដោយចេតនាក្តី អចេតនាក្តី នូវការអនុវត្តផែនការ ដ៏ក្តៅងងឹតបែបនេះ គឺគ្រាន់តែធ្វើជាអាយ៉ងគេ ហើយត្រូវគេជម្រុញឱ្យធ្វើសកម្មភាពប្រឆាំង នឹងប្រទេសខ្លួនឯង ។

នៅពេលដែល ស្ថានការណ៍នៅតាមបណ្តោយព្រំដែន ភាគខាងលិចរបស់យើង នៅអាចគ្រប់គ្រងបាននៅឡើយប្រទេសកម្ពុជាជាដំបូង ត្រូវខិតខំដោះស្រាយបញ្ហាមនុស្សធម៌ មួយចំនួន ដូចជាជោគវាសនា ពលរដ្ឋខ្មែរជាង២០ម៉ឺននាក់ ដែលបច្ចុប្បន្នកំពុងរស់នៅធ្វើការនៅប្រទេសថៃពីព្រោះគ្មានការងារធ្វើនៅប្រទេសកម្ពុជា ដោយសារបញ្ហាសេដ្ឋកិច្ច និងសង្គម ដែលរដ្ឋាភិបាលលោក*ហ៊ុនសែន* មិនអាចដោះស្រាយបាន ។

ល្បែងនយោបាយដែលលោក*ហ៊ុន សែន* កំពុងតែលេងសព្វថ្ងៃពិតជាគ្មានប្រយោជន៍អ្វីដល់កម្ពុជាទេ ។ ផ្ទុយទៅវិញល្បែងនេះជាល្បែងគ្រោះថ្នាក់ ។យើងមិនត្រូវអនុញ្ញាត ឱ្យលោក*ហ៊ុន សែន* បន្តធ្វើអោយមានគ្រោះថ្នាក់ដល់សន្តិសុខប្រទេស ដល់ប្រទេសយើងទេ ។ ប្រទេសកម្ពុជាត្រូវរក្សាអព្យាក្រឹត្យភាពនៅក្នុងជម្លោះផ្ទៃក្នុង របស់ប្រទេសដទៃទៀត ។ការរាលដាលណាមួយពីភាពតានតឹង ឬភាពជ្រួលច្របល់នៅប្រទេសថៃអាចធ្វើអោយខូចខាត ដល់ប្រទេសកម្ពុជាយ៉ាងធ្ងន់ធ្ងរ ។ ការគិតខុសរបស់លោក*ហ៊ុន សែន* នៅពេលគាត់ចាក់ប្រេង លើភ្លើងនៅប្រទេស ជិតខាងមួយនោះ នឹងនាំមកនូវផលអាក្រក់ គឺលោក*ហ៊ុន សែន* អាចឆេះដៃ និងឆេះខ្លួន តែវាអាចលើសពីនេះទៀត គឺប្រទេសកម្ពុជាទាំងមូល អាចឆេះសន្ធោសន្ធៅតែម្តង ដូចដែលបទពិសោធន៍ ពីអតីតកាលបានបង្ហាញ អោយឃើញស្រាប់នៅពេលណាដែលយើងលូកដៃទៅកាន់ ជើងភាគីជម្លោះម្ខាងប្រឆាំងទៅនឹងភាគីជម្លោះម្ខាងទៀតនៅក្នុងជម្លោះផ្ទៃក្នុង របស់ប្រទេសជិតខាងនោះ ៕

ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៩

**សម រង្ស៊ី**

អ្នកតំណាងរាស្ត្រ

ប្រធានគណបក្សសម រង្ស៊ី

---

**តមកពីទំព័រទី២ ៥**

ជនល្មើស ស្រែកឡូឡា ព្រមានគេឯង ដោយប្រើឈ្មោះ ថ្នាក់ដឹកនាំ មកគំរាមកំហែង ដល់សមត្ថកិច្ច ដោយមិនដឹងថាខ្លួនធ្វើបែបនេះ ខុសនោះឡើយ ។ តែអ្វីដែលសោកស្តាយបុរសរូបនេះ មិនត្រូវបានសមត្ថកិច្ច ធ្វើការឃាត់ខ្លួនទេ ដោយសារតែអំណាចដុល្លារនិងទំណាចតួនាទីខ្ពស់នោះ បានត្រឹមតែអញ្ជើញឱ្យទៅទីស្នាក់ការនគរបាល នៅមូលដ្ឋាននោះ ដើម្បីសួរនាំអំពីមូលហេតុប៉ុណ្ណោះ ហើយក៏ឱ្យវិលត្រឡប់ទៅលំនៅដ្ឋានវិញ ។

ជនល្មើស ដែលប្រើប្រាស់កាំភ្លើង ដែលកាសែតដើមអំពិលមិនប្រាប់អត្តសញ្ញាណនេះ ក៏គេស្គាល់ច្បាស់ដែរ ពីព្រោះលំនៅដ្ឋាន និងកន្លែងប្រព្រឹត្ត បាញ់បោះរបស់ជនល្មើសនោះ ធ្វើឱ្យសមត្ថកិច្ចមូលដ្ឋាន បានដឹងនិងបានកោះហៅ ទៅសួរនាំទៀតផង ។

ករណីជនល្មើសទាំងពីរដែលមនុស្សធុននេះ ត្រូវលោក*ហ៊ុន សែន* ផ្តល់រហស្សនាមថា ជាប្រុសទំនើងនោះ មិនត្រូវបានច្បាប់ផ្តន្ទាទោសទេ ដោយសារតែម្នាក់ ជាមន្ត្រីអង្គរក្សអ្នកធំ និងម្នាក់ទៀត មានប្រាក់ និងមានអំណាច ។ ចុះស្រីទំនើង*ខែ ដារ៉ា* អាងប្តីជាទីប្រឹក្សាលោក*ហេង សំរិន* ប្រធានរដ្ឋសភានិងជាប្រធានកិត្តិយស គណបក្សប្រជាជន ក៏កំពុងកាន់អំណាចដែរ បែរជាមានទោស ១៨ឆ្នាំទៅហើយ ដែលទោសនេះត្រូវលោក*ហ៊ុន សែន* ថ្លែងជាសាធារណៈថា តិចតួចនៅឡើយ មិនទាន់សមល្មម នឹង*ខែ ដារ៉ា* បានប្រព្រឹត្តនោះទេ ។

បញ្ហានេះហើយបានជាធ្វើឱ្យមានការរិះគន់លេចចេញពាក្យថា ប្រុសទំនើងបាញ់បោះស្គាល់អត្តសញ្ញាណដែរ ប៉ុន្តែមិនស្ថិតនៅក្នុង សំណាញ់ច្បាប់, តែ*ខែ ដារ៉ា* បែរជាមានទោស និងត្រូវបានបណ្តាញព័ត៌មានដែលរហូតដល់ទៅ ស្ថានីយ៍ទូរទស្សន៍ផងនោះចាក់ផ្សាយអំពីសកម្មភាពទំនើងរបស់នាង ។

ទោះយ៉ាងណា អ្នកភ្នំពេញនិយាយថាបទបញ្ជារបស់លោក*ហ៊ុន សែន* ហាក់ដូចជានៅមានប្រសិទ្ធភាព តិចតួចនៅឡើយ ចំពោះការអនុវត្តន៍ ទៅលើពួកជនទំនើងដែលប្រើប្រាស់អាវុធខុសច្បាប់នោះ, ហើយគេរង់ចាំមើលថា តើប្រុសទំនើង ទាំង២រូបនេះពិតជាគេចផុតពីសំណាញ់ច្បាប់ដែលពួកគេលាក់បាំងមិនឱ្យលោក*ហ៊ុន សែន* ដឹងឮ ជារហូតឬ ?

បើមានអ្នកជាប់គុកមានអ្នករួចខ្លួនដដែលនោះ គួរតែដោះលែងស្រីទំនើង*ខែ ដារ៉ា*វិញទៅ ដើម្បីឱ្យស្មើភាពគ្នាហើយរាស្ត្រតូចតាចចាំតែរត់រកកន្លែងលាក់ខ្លួនពួនអាត្មាតទៅទៀតចុះ បើអ្នកមានកំហុសហើយ បែរជាគ្មានទោសនោះ ៕

---

**តមកពីទំព័រទី៤ គ**

ប្រធានព្រឹទ្ធសភា លោក *ហេង សំរិន*ប្រធានកិត្តិយសគណបក្សនេះ និងជាប្រធានសភាជាតិ លោក*ហោ ណាំហុង* ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស លោក *គាត ឈន់* ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លោក*ស៊ីមកា*និងលោក*អ៊ុកប៊ុនឈឿន* សមាជិកព្រឹទ្ធសភាពីររូបរបស់គណបក្សប្រជាជន អស់លោកមិនបានផ្តល់ចម្លើយបញ្ជាក់ថានឹងចូលរួមផ្តល់សក្ខីកម្ម ឬធ្វើសាក្សីដើម្បីបង្ហាញភស្តុតាងករណីដែលអស់លោកបានដឹងនៅក្នុងឧក្រិដ្ឋកម្មកាលជំនាន់កម្ពុជាប្រជាធិបតេយ្យខ្មែរក្រហមនោះទេ ។

មន្ត្រីចៅក្រមខាងភាគីអង្គការសហប្រជាជាតិនៃសាលាក្តីនេះ ទាមទារឱ្យមានការអនុវត្តទៅតាមច្បាប់ សម្រាប់កាត់ទោសអតីតមេដឹកនាំខ្មែរក្រហមដែលជាកត្តាកំណត់ចាំបាច់ដើម្បីនឹងនាំខ្លួនជនទាំងឡាយដែលពាក់ព័ន្ធក្នុងឧក្រិដ្ឋកម្មកាលជំនាន់នោះមកជំនុំជម្រះនៅអង្គសវនាការតុលាការខ្មែរក្រហម ជាពិសេសករណីសំណុំរឿង០០២អំពីមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់៤រូប ។

លោកបណ្ឌិត *ភីធី ម៉ាក់វែល* ដែលធ្លាប់និពន្ធសៀវភៅស្តីពីអំពើឃោរឃៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យខ្មែរក្រហម ក្រោយចំណងជើងថា "*ការប្រឈមនឹងសេចក្តីស្លាប់ក្នុងប្រទេសកម្ពុជា*" នោះ លោកបានធ្វើការកត់សម្គាល់ថា ឆន្ទៈរបស់អង្គការសហប្រជាជាតិប្រហែលជាត្រូវបញ្ចប់វត្តមានរបស់ខ្លួននៅក្នុងសាលាក្តី ។

ជាហេតុផលនោះអ្នកសង្កេតការណ៍រូបនេះបានលើកចង្អុលទៅដល់អ្វីដែលអង្គការសហប្រជាជាតិធ្លាប់បានធ្វើរួចមកហើយក្នុងអតីតកាល ដែលទុកឱ្យលោក *ហ៊ុន សែន* ធ្វើអ្វីៗតាមអំពើចិត្ត ដូចករណីនៅក្រោយការបោះឆ្នោតរៀបចំឡើងដោយអ៊ុនតាក់ក្នុងខែឧសភា ១៩៩៣ ដោយគណបក្សប្រជាជនបានចាញ់ឆ្នោត និងបានប្រើកម្លាំងបាយយោធាតវ៉ាទាមទារចំណែកអំណាចបានជាងពាក់កណ្តាលវិញនោះ ។

តាមសេចក្តីថ្លែងរបស់លោកសាស្ត្រាចារ្យបណ្ឌិត *ភីធី ម៉ាក់វែល* នោះថា ឆន្ទៈនៃរដ្ឋាភិបាលលោក *ហ៊ុន សែន* មានកម្រិតក្នុងការគាំទ្រដំណើរការរបស់តុលាការដែលកំពុងបំពេញការងារជំនុំជម្រះលើអតីតមេដឹកនាំខ្មែរក្រហម ហើយគឺជារឿងដែលលោកពិពណ៌នាថាជាការសាកល្បងរបស់សាលាក្តីកូនកាត់អង្គការសហប្រជាជាតិកម្ពុជានេះ ។

មន្ត្រីជាន់ខ្ពស់ម្នាក់របស់គណបក្សប្រជាជនដែលធ្លាប់ធ្វើការក្នុងរបបខ្មែរក្រហម ហើយបច្ចុប្បន្នជាសមាជិកព្រឹទ្ធសភារបស់គណបក្សនេះលោក *អ៊ុក ប៊ុនឈឿន*ជាមនុស្សម្នាក់នៃឥស្សរជនគណបក្សកាន់អំណាចច្រើននាក់ទៀតដែលត្រូវសហចៅក្រមស៊ើបអង្កេតភាគីអង្គការសហប្រជាជាតិកោះអញ្ជើញទៅផ្តល់ព័ត៌មាននោះ លោកបានបដិសេធការចូលរួម ។

លោក*អ៊ុក ប៊ុនឈឿន* បាននិយាយថា "*ខ្ញុំបានជំរាបរួចហើយថា ខ្ញុំមិនអាចធ្វើអត្ថាធិប្បាយរឿងនេះ ។ សូមអរគុណ ខ្ញុំអស់យោបល់ហើយ*" ។

នាយករដ្ឋមន្ត្រី *ហ៊ុន សែន* ផ្ទាល់ជាញយដងបានប្រកាសជាសាធារណៈ ដែលជាតម្រុយប្រាប់ឱ្យគេដឹងបានថា គាត់មិនមានឆន្ទៈនឹងធ្វើសហប្រតិបត្តិការពេញលេញជាមួយតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនោះទេ ។ គាត់បានថ្លែងអំពីការដែលគាត់សុខចិត្តឱ្យតុលាការនេះបរាជ័យជាជាងឱ្យមានការនាំខ្លួនអតីតមេដឹកនាំខ្មែរក្រហមច្រើននាក់ថែមទៀតមកកាត់ទោស ដែលគាត់អធិប្បាយថាអាចនាំឱ្យផ្ទុះសង្គ្រាមជាសង្គ្រាមដែលតាមពួកអ្នកសង្កេតការណ៍ថា មិនអាចកើតឡើងជាថ្មីឡើយ ដោយសារអតីតយុទ្ធជនខ្មែរក្រហមគ្រប់គ្នាដឹងការពិតហើយមិនចង់ធ្វើសង្គ្រាមទៀត ។

ការវិវឌ្ឍន៍នៃដំណើរការនេះគឺភាគីកម្ពុជាដែលតែងតាំងដោយរដ្ឋាភិបាលលោក *ហ៊ុន សែន* នៅក្នុងសាលាក្តីនោះ មិនមានសម្លេងគ្រប់គ្រាន់ដើម្បីនឹងរាំងខ្ទាស់កិច្ចប្រឹងប្រែងរបស់ចៅក្រមខាងភាគីអង្គការសហប្រជាជាតិដើម្បីនាំខ្លួនអតីតមេដឹកនាំខ្មែរក្រហមច្រើននាក់ថែមទៀតនោះឡើយ ។ ប៉ុន្តែលោក *ហ៊ុន សែន* បាននិយាយថា បើទោះជាយ៉ាងនេះក៏ដោយ ក៏ការងារមិនអាចទៅមុខរួច ដោយសារតែច្បាប់ចងមិនឱ្យចៅក្រមភាគីអង្គការសហប្រជាជាតិធ្វើការសម្រេចអ្វីៗបានដោយគ្មានការចូលរួមរបស់ចៅក្រមអ្នកច្បាប់ខាងកម្ពុជា ។

រឿងនេះអ្នកច្បាប់ឯករាជ្យដែលតាមដានការវិវឌ្ឍន៍តុលាការខ្មែរក្រហមនិយាយថា អ្វីដែលសាលាក្តីនេះកំពុងធ្វើ គឺជាច្បាប់ ហើយរដ្ឋាភិបាលកម្ពុជាអស់អាណត្តិការងាររបស់ខ្លួនដែលបានចូលរួមបង្កើតសាលាក្តីជាបញ្ហានយោបាយនោះហើយ ។ ដូច្នេះអ្វីៗត្រូវស្ថិតនៅក្នុងការសម្រេចរបស់ចៅក្រមដែលតុលាការគួរធ្វើតាមប្រយោជន៍របស់តុលាការអនុលោមទៅតាមច្បាប់ផ្សេងពីកាលមុនវាជារឿងនយោបាយដែលរដ្ឋាភិបាលជាអ្នកដោះស្រាយ ហើយឥឡូវវាជារឿងច្បាប់ដែលជាភារកិច្ចរបស់តុលាការនោះ ៕

**ក្រុមហ៊ុនភាពយន្ត ជនបទ**

**មានទទួលបញ្ចាំង ខ្សែភាពយន្តខ្នាតធំ ក្នុងពិធីផ្សេងៗ មានពន្លឺច្បាស់ និងមានលក់ម៉ាស៊ីន បញ្ចាំងខ្សែភាពយន្ត ទំនាក់ទំនងតាមទូរស័ព្ទ**

**012 66 44 67**

**015 66 44 67**

Khmer Machas Srok News

**សារព័ត៌មាន "ខ្មែរម្ចាស់ស្រុក" ប្រចាំថ្ងៃ ទំព័រទី០៤**
Tel: 017 360 678 , E-mail : kmsnews@gmail.com

**តមកពីទំព័រទី១ ខ**

គុក៧ឆ្នាំ និងការបង់ប្រាក់ពិន័យ១០លានរៀល ជារឿងធ្វើឱ្យគេមើលឃើញថាអំណាចនៅកម្ពុជាលើកតម្កើង ការអនុវត្តច្បាប់ហើយពូកែខ្លាំងតែជាតិឯងនោះ ខាងគណបក្សសមរង្ស៊ីកំពុងបន្តការងាររកស្នាមមេដៃគាំទ្រពីប្រជារាស្ត្រខ្មែរ ដើម្បីឱ្យមានការប្រគល់អភ័យឯកសិទ្ធិសភាជូនលោក *សម រង្ស៊ី*វិញ។

លោក *យឹម សុវណ្ណ* សមាជិកសភាគណបក្សសមរង្ស៊ី និងជាអ្នកនាំពាក្យរបស់គណបក្សនេះផង បានថ្លែងអំពីការបន្តសកម្មភាពប្រមូលស្នាមមេដៃរបស់ប្រជារាស្ត្រនៅតាមមូលដ្ឋាន តាមរយៈសកម្មជនរបស់គណបក្សសមរង្ស៊ី ក្នុងគោលដៅដាក់ថ្វាយព្រះមហាក្សត្រ និងជូនទៅប្រធានសភាជាតិរកអន្តរាគមន៍សម្រាប់ការបានអភ័យឯកសិទ្ធិសភារបស់លោក *សម រង្ស៊ី* មកវិញ។

លោក *យឹម សុវណ្ណ* បានមានប្រសាសន៍យ៉ាងនេះ"*យើងកំពុងឱ្យរចនាសម្ព័ន្ធរបស់យើងធ្វើការប្រមែប្រមូលស្នាមមេដៃដើម្បីរៀបចំជាញត្តិស្នើសុំទៅព្រះករុណាព្រះមហាក្សត្រព្រទានព្រះរាជតម្រិះអន្តរាគមន៍ផ្តល់អភ័យឯកសិទ្ធិសភាជូនឯកឧត្តម សម រង្ស៊ី វិញ*"។

ទន្ទឹមនឹងនេះដែរ គណបក្សសមរង្ស៊ីក៏នឹងធ្វើលិខិតមួយជូនប្រធានសភាជាតិដើម្បីគោលដៅដូចគ្នា។ លោក *យឹម សុវណ្ណ* បានអធិប្បាយត្រង់នេះ "*សភាជាតិក៏ធ្វើការដូចគ្នាដែរ*" ដើម្បីនឹងរកការប្រគល់ដោយសភាជាតិផ្តល់អភ័យឯកសិទ្ធិសភាជូនលោក *សម រង្ស៊ី*វិញនោះ។

តាមការថ្លែងរបស់លោក *យឹម សុវណ្ណ* នោះ លិខិតដើម្បីនឹងដាក់ថ្វាយព្រះករុណាព្រះមហាក្សត្រសម្តេចព្រះបរមនាថ *នរោត្តម សីហមុនី* ក៏ដូចជាដាក់ជូនលោកប្រធានសភាជាតិ *ហេង សំរិន* នោះ នឹងធ្វើនៅដំណាច់ខែធ្នូខាងមុខនេះ។

សមាជិកសភាគណបក្សប្រជាជន នៃនាយករដ្ឋមន្ត្រី*ហ៊ុន សែន* បានធ្វើការកោះប្រជុំយ៉ាងប្រថុចប្រញ៉ាចចេញសេចក្តីសម្រេចកាលព្រឹកថ្ងៃទី១៦ ខែវិច្ឆិកា ដោយមិនអនុញ្ញាតិឱ្យតំណាងអង្គទូត ក៏ដូចជាអ្នកសារព័ត៌មានចូលរួមស្តាប់នោះទេ អំពីការដែលពួកគេបានដកព្យួរអភ័យឯកសិទ្ធិសភារបស់លោក *សម រង្ស៊ី* ។ គឺជាវិធានការដែលធ្វើឡើងនៅក្រោយមានការប្តឹងផ្តល់របស់អាជ្ញាធរស្រុកចន្ទ្រាខេត្តស្វាយរៀងតាមផ្លូវតុលាការដែលមិនឯករាជ្យ ហើយបញ្ជូនសំណើសុំទៅក្រសួងយុត្តិធមិដាក់ចូលទៅរកសេចក្តីសម្រេចរបស់សភាជាតិព្យួរអភ័យឯកសិទ្ធិសភាលោក *សម រង្ស៊ី* នៅបន្ទាប់ពីនាយករដ្ឋមន្ត្រីយួន *ង្វៀន តាន់ឌុង*បានបញ្ចេញប្រតិកម្មយ៉ាងខ្លាំងក្លាទាមទារឱ្យមេដឹកនាំកម្ពុជាចាត់ការប្រឆាំងនឹងលោក *សម រង្ស៊ី* ។

ចំណាត់ការរបស់អំណាចត្រួតត្រានៅប្រទេសកម្ពុជាក្រោយការទាមទាររបស់មេដឹកនាំយួននោះធ្វើឡើងដោយផ្អែកទៅលើអ្វីជាការដែលប្រជារាស្ត្រខ្មែរម្ចាស់ដីស្រែនៅភូមិកោះក្បានកណ្តាល ឃុំសំរោង ស្រុកចន្ទ្រាខេត្តស្វាយរៀងរួមជាមួយលោក *សម រង្ស៊ី* តំណាងរាស្ត្រមួយរូបដែលត្រូវចេញមុខធ្វើជាតំណាងរបស់ប្រជារាស្ត្រ និងប្រយោជន៍ជាតិបានសម្រេចដកបង្គោលតម្រុយ៦ដើមជុំវិញទីតាំងបង្គោលល័ក្សបណ្តោះអាសន្នលេខ១៨៥ ជាបង្គោលដែលគណៈកម្មាធិការព្រំដែននៃប្រទេសជិតខាងទាំងពីរកម្ពុជា-វៀតណាមចំកណ្តាលដីស្រែប្រជាកសិករខ្មែរ។

ការដកបង្គោលដែលបានប្រព្រឹត្តឡើងកាលពីថ្ងៃទី២៥ ខែតុលាក្រោយពីសមាជិកសភាគណបក្សសមរង្ស៊ីបានហែរកឋិនចូលវត្តអង្គរំដិញ ឃុំសំរោង ស្រុកចន្ទ្រាខេត្តស្វាយរៀងនោះ គឺជាប្រតិកម្មរបស់សមាជិកសភាកម្ពុជា ជាតំណាងមួយរូបរបស់ប្រទេសជាតិ និងតំណាងផលប្រយោជន៍ប្រជារាស្ត្រតវ៉ាចំពោះការបោះបង្គោលនោះ គឺជាការតវ៉ាដែលប្រជារាស្ត្រម្ចាស់ដីស្រែចំការបានចាប់ផ្តើមមានប្រតិកម្មដាក់បណ្តឹងឱ្យរកដំណោះស្រាយជួយការពារដីស្រែរបស់ប្រជាកសិករខ្មែរ ប៉ុន្តែ១៦ខែនៃការតវ៉ារបស់ប្រជារាស្ត្ររកយុត្តិធមិពុំមានការឆ្លើយតបដោយរដ្ឋាភិបាលនៃគណបក្សប្រជាជនកាន់អំណាច ឬអាជ្ញាធរថ្នាក់ណាដែលត្រួតត្រាដោយគណបក្សនេះនោះទេ។

បញ្ហានោះ ក៏ដូចជាការដកព្យួរអភ័យឯកសិទ្ធិសភារបស់លោក*សម រង្ស៊ី*ដែលគណបក្សរបស់លោកបានរិះគន់ធ្ងន់ៗថាជាចំណាត់ការធ្វើឡើងក្រោមគំនាបឥទ្ធិពលនយោបាយរបស់មេដឹកនាំយួនហាណូយ គឺជារឿងមួយទាក់ទាញប្រតិកម្ម និងការតាមដានរបស់មជ្ឈដ្ឋានទាំងអស់ក្នុងប្រទេសកម្ពុជា ក៏ដូចជាមជ្ឈដ្ឋានអ្នកនយោបាយជាន់ខ្ពស់នៃសហរដ្ឋអាមេរិក សហភាពអឺរ៉ុបនិងអង្គការអន្តរជាតិទាំងនោះផងដែរ រាប់ទាំងអង្គការសហប្រជាជាតិផង។

ហើយដូចគ្នាដែរ ការដែលនាយករដ្ឋមន្ត្រីកម្ពុជាលោក *ហ៊ុន សែន* ធ្វើតាមការស្នើសុំរបស់គណបក្សភឿថៃ នៃឧត្តមសេនីយ៍សៀម *ឆាវលិត យ៉ុងឆៃយ៉ុត* រួមជាមួយស្ត្រីជនជាតិសៀមម្នាក់ជាម្តាយរបស់ចារបុរសសៀម *ស៊ីវ៉ារ៉ាក់ ជុធិពង់* ដែលមានការចូលរួមរបស់មេធាវីខ្មែរម្នាក់ការពារក្តីឱ្យចារបុរសសៀមនោះ ដាក់សុំទៅព្រះករុណាព្រះមហាក្សត្រខ្មែរប្រទានការលើកលែងទោសដល់ជនដែលរដ្ឋាភិបាលខ្លួនឯងបានចោទប្រកាន់ថា គឺចារកម្មប៉ះពាល់ដល់សន្តិសុខជាតិកម្ពុជា ការលើកលែងទោសនេះក៏បានទាក់ទាញប្រតិកម្មចំណាប់អារម្មណ៍ដោយការភ្ញាក់ផ្អើលពីមជ្ឈដ្ឋាននានាក្នុងប្រទេសកម្ពុជានិងពីក្រៅប្រទេសនោះដែរ។

នេះគឺជាករណីខុសគ្នាស្រឡះដែលលោក *សម រង្ស៊ី* សមាជិកសភាកម្ពុជាគ្រាន់តែបានបំពេញការតព្វកិច្ចជាអ្នកតំណាងរាស្ត្រចេញមុខឈឺឆ្អាលដល់ការលំបាកទាំងឡាយរបស់ប្រជាកសិករខ្មែរដែលបានបាត់បង់ដីធ្លីតាមតំបន់ជាយដែនដោយការបោះបង្គោលព្រំដែន ហើយដែលសមាជិកសភាគណបក្សប្រជាជន និងរដ្ឋាភិបាលមិនបានជួយប្រជារាស្ត្រឯងនោះ លោក*សម រង្ស៊ី* បែរជារងនូវគំនាបគាបសង្កត់ដកព្យួរអភ័យឯកសិទ្ធិសភារបស់លោក ជាមួយបទចោទប្រកាន់ប្តឹងទៅតុលាការក្នុងកម្រិតថាបំផ្លាញទ្រព្យសម្បត្តិសាធារណៈ និងញុះញង់ឱ្យមានការស្អប់ពូជសាសន៍ឱ្យប្រព្រឹត្តឧក្រិដ្ឋកម្មមិនបានសម្រេចផលទៅវិញ។

គឺជាករណីខុសផ្ទុយគ្នាទាំងស្រុងនឹងជនជាតិសៀម*ស៊ីវ៉ារ៉ាក់ ជុធិពង់* អាយុ៣១ឆ្នាំ ដែលរដ្ឋាភិបាលលោក*ហ៊ុន សែន*ខ្លួនឯងបានចោទប្រកាន់ដោយភ្ជាប់ជាមួយភស្តុតាងច្បាស់លាស់ថា ជននេះបានប្រព្រឹត្តចារកម្មលួចឯកសារព័ត៌មានជើងហោះហើររបស់លោក *ថាក់ស៊ីន ស៊ីណាវ៉ាត្រា* និងរបស់លោក *ហ៊ុន សែន* ដូច្នេះចាត់ទុកថា ជាការគំរាមដល់សន្តិសុខជាតិកម្ពុជា យោងតាមច្បាប់របស់កម្ពុជា បែរជានាយករដ្ឋមន្ត្រីកម្ពុជាសម្រេចឱ្យមានការដោះលែងជនជាតិសៀមនេះយ៉ាងស្រួល។

រដ្ឋមន្ត្រីក្រសួងព័ត៌មានដែលជាអ្នកនាំពាក្យរដ្ឋាភិបាលកម្ពុជាបានប្រាប់អ្នកសារព័ត៌មានថា ជនជាតិសៀមនេះ នឹងត្រូវដោះលែងនៅថ្ងៃចន្ទ ទី១៤ ខែធ្នូ។

ពួកអ្នកសង្កេតការណ៍ ទាំងមជ្ឈដ្ឋានមន្ត្រីអង្គការការពារសិទ្ធិមនុស្សកម្ពុជាមើលឃើញថា បញ្ហាដោះលែងជនជាតិសៀម *ស៊ីវ៉ារ៉ាក់ ជុធិពង់* ពុំធ្វើឱ្យមុខមាត់ប្រទេសកម្ពុជាល្អ ហើយក៏ពុំធ្វើឱ្យកិត្តិយសរបស់លោក *ហ៊ុន សែន* រួចពីការនិន្ទានោះទេ។ ការត្រួតត្រារបស់គណបក្សប្រជាជនពុំបានលើកតម្កើងការគោរពច្បាប់ ឬនីតិរដ្ឋ ដូចដែលជាពាក្យអះអាងចេញពីមាត់នាយករដ្ឋមន្ត្រី និងមន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាលជាហូរហែរនោះឡើយ។

គឺថាសន្តិសុខរបស់ប្រទេសកម្ពុជាទាំងមូល នីតិរដ្ឋដែលកម្ពុជាគួរតែបានការគោរពការ លើកតម្កើង និងការអនុវត្តច្បាប់ដ៏ត្រឹមត្រូវ ត្រូវពួកអ្នកកាន់អំណាច និងនិយាយឱ្យចំគឺនាយករដ្ឋមន្ត្រី *ហ៊ុន សែន* ផ្ទាល់តែម្តងធ្វើឱ្យអាប់ឱនដោយសារតែការសម្រេចជាឆន្ទៈរបស់បុគ្គលកាន់អំណាចលើកលែងទោសឱ្យចារបុរសសៀម *ស៊ីវ៉ារ៉ាក់ ជុធិពង់* ក្រោយពីការស្នើសុំរបស់គណបក្សសៀមមួយនៅបាងកក រួមជាមួយម្តាយរបស់ចារបុរសសៀម និងមេធាវីខ្មែរការពារក្តីឱ្យជនល្មើសនេះដែលគំរាមសន្តិសុខកម្ពុជាទាំងមូល ហើយជាករណីខុសទាំងស្រុងនឹងលោក *សម រង្ស៊ី* ដែលពុំបានធ្វើអ្វីឱ្យប៉ះពាល់សន្តិសុខ និងផលប្រយោជន៍ប្រទេសកម្ពុជា ក្រៅពីជួយប្រទេសជាតិ និងប្រជារាស្ត្រខ្មែរនោះទេ។

លោក *យឹម សុវណ្ណ* អ្នកនាំពាក្យរបស់គណបក្សសមរង្ស៊ីបានមានប្រសាសន៍អធិប្បាយថា លោក*សមរង្ស៊ី* មិនបានប្រព្រឹត្តអ្វីជាកំហុស ដូចដែលតុលាការបានធ្វើការចោទប្រកាន់នោះឡើយ។

ហើយប្រជារាស្ត្រខ្មែរម្ចាស់ដីស្រែដែលត្រូវគណកម្មាធិការព្រំដែនដឹកនាំដោយលោក *វ៉ា គឹមហុង* រួមជាមួយសមភាគីយួនឆ្លងខ្សែព្រំដែនពីមុនរំលងហួសប្រឡាយយុទ្ធសាស្ត្រចូលទៅមកបោះដាំបង្គោលតម្រុយលើដីស្រែប្រជារាស្ត្រខ្មែរចំងាយច្រើនរយម៉ែត្រពីខ្សែព្រំដែនមុន នោះប្រជារាស្ត្រខ្មែរម្ចាស់ដីស្រែផ្ទាល់ដឹងយ៉ាងច្បាស់ហើយទាំងអះអាងថា លោក *សម រង្ស៊ី* មិនបានប្រព្រឹត្តអ្វីខុសដូចការចោទប្រកាន់របស់អាជ្ញាធរកម្ពុជា។ ព្រោះតែរឿងនេះបានជាប្រជារាស្ត្រប្រកាសថា ឱ្យតុលាការនិងរដ្ឋាភិបាលដាក់ទោសពួកគាត់ជាប្រជារាស្ត្រម្ចាស់ដីស្រែជាជាងតាមធ្វើទុក្ខបុកម្នេញលោក *សម រង្ស៊ី* ដែលគ្រាន់តែចេញមុខការពារផលប្រយោជន៍ប្រជារាស្ត្រខ្មែរ និងការពារបូរណភាពទឹកដីកម្ពុជានោះ៕

---

**តមកពីទំព័រទី១ គ**

មានអតីតកាលជាកម្មាភិបាលខ្មែរក្រហមក្នុងអំឡុងនៃការកាប់សម្លាប់មនុស្សយ៉ាងរង្គាលនោះ នៅតែបដិសេធន៍មិនព្រមធ្វើសហប្រតិបត្តិការពេញលេញផ្អែកទៅតាមមូលដ្ឋានច្បាប់សម្រាប់វិនិច្ឆ័យអតីតមេដឹកនាំខ្មែរក្រហមទេនោះអង្គការពិភពលោកជាដៃគូរពោលគឺអង្គការសហប្រជាជាតិពុំមានជម្រើសណាល្អក្រៅពីដកខ្លួនពីការកាត់ក្តីនេះឡើយ ។គឺជាជម្រើសមួយដែលអ្នកសង្កេតការណ៍រូបនេះមើលឃើញថា ដើម្បីចៀសវាងនូវការបាក់មុខ និងភាពមិនគួរឱ្យជឿទុកចិត្តបានក្នុងដំណើរការរកយុត្តិធមិមិនមានលក្ខណៈជាយុត្តិធមិនោះ។

លោកសាស្ត្រាចារ្យ *ភីធី ម៉ាក់វែល* បានមានប្រសាសន៍យ៉ាងនេះ "*បើរដ្ឋាភិបាលកម្ពុជាបដិសេធមិនធ្វើសហប្រតិបត្តិការពេញលេញទេនោះ អង្គការសហប្រជាជាតិគ្មានជម្រើសផ្សេងទៀតណាជាជាងដកខ្លួនពីការកាត់ទោសនោះទេ បើពុំដូច្នេះទេ អង្គការសហប្រជាជាតិនឹងបាក់មុខ ហើយក៏បាត់បង់នូវភាពគួរឱ្យជឿទុកចិត្តបាន*"នៅក្នុងការចូលរួមក្នុងអង្គជំនុំជម្រះវិសាមញ្ញ ឬការកាត់ទោសមេដឹកនាំខ្មែរក្រហមនោះ។

អ្វីដែលជាការកត់សម្គាល់របស់អ្នកសង្កេតការណ៍អាមេរិកាំងរូបនេះអំពីកង្វះសហប្រតិបត្តិការដោយសុទ្ធចិត្តរបស់មន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលកាន់អំណាចនៅកម្ពុជានោះ ការដែលមន្ត្រីថ្នាក់ខ្ពស់កំពូល៧ទាំងក្នុងរដ្ឋាភិបាល ទាំងក្នុងសភាជាតិ ទាំងក្នុងព្រឹទ្ធសភា ដែលមានអតីតកាលជាកម្មាភិបាលខ្មែរក្រហម ដូច្នេះអាចដឹងរឿងរ៉ាវនៃឧក្រិដ្ឋកម្មកាលជំនាន់នោះ អស់លោក៦នាក់បានត្រូវសាលាក្តីខាងភាគីអង្គការសហប្រជាជាតិកោះអញ្ជើញចូលផ្តល់សក្ខីកម្ម។

ប៉ុន្តែអស់លោកទាំង៦នាក់នេះដូចជាលោក*ជាស៊ីម*ប្រធានគណបក្សប្រជាជន ក៏ដូចជា

**តទៅទំព័រទី៣ គ**

---

**តមកពីទំព័រទី១ ក**

**ហើយក៏ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយរាប់ទាំងឧក្រិដ្ឋកម្មប្រឆាំងនឹងប្រជារាស្ត្រខ្មែរខ្លួនឯង និងប្រទេសកម្ពុជានោះផងដែរ។**

**ប៉ុន្តែទន្ទឹមនឹងនោះដែរ ក៏មានការលើកសំណួរឡើងដោយការឆ្ងើងឆ្ងល់ថា តើការថ្លែងចេញពីមាត់របស់នាយករដ្ឋមន្ត្រីនោះ គឺជាភាសានៃសុច្ឆន្ទៈ ឬក៏ជាចេតនាការពារខ្លួនពីការរិះគន់របស់មជ្ឈដ្ឋានប្រជារាស្ត្រខ្មែរទូទៅជាជនរងគ្រោះពីអំពើពុករលួយ របស់ពួកអ្នកសង្កេតការណ៍សកម្មជនសិទ្ធិមនុស្សអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ និងរបស់សហគមន៍ម្ចាស់ជំនួយអន្តរជាតិ ? មជ្ឈដ្ឋាន៣ចុងក្រោយសហគមន៍អន្តរជាតិបង្ហូរលុយថវិកាជំនួយជាការបង់ពន្ធរបស់ពលរដ្ឋគេមកឱ្យកម្ពុជា ក្នុងបំណងជួយប្រជារាស្ត្រខ្មែរមួយឆ្នាំៗពីចន្លោះ៦រយលានដុល្លារ ទៅ១ពាន់លានដុល្លារ តាមរយៈរដ្ឋាភិបាល ។ហើយអង្គការសង្គមស៊ីវិលសកម្មជនសិទ្ធិមនុស្សនៅកម្ពុជា និងពិភពលោក ក៏ធ្វើការងារក្នុងគោលដៅបោសសំអាតអំពើពុករលួយដែលកំពុងចាក់ឫសយ៉ាងជ្រៅបំផ្លាញទាំងថវិកាជាតិ ថវិកាជំនួយអន្តរជាតិ ក៏ដូចជាធនធានរបស់ប្រទេសក្នុងគ្រាដែលប្រជារាស្ត្រខ្មែរជាអ្នកត្រូវទទួលផលនៃជំនួយបរទេស ក៏រងផលប៉ះពាល់យ៉ាងធ្ងន់នៃអំពើពុករលួយនោះដែរ។**

**ការប្រកាសរបស់លោកនាយករដ្ឋមន្ត្រីចាត់ទុកបានថាជាការភ្ញាក់រលឹកមួយ ថ្វីបើគេអាចប្រើពាក្យថា យឺតពេលក៏ដោយនោះ ក៏នៅមិនហួសពេលនៅឡើយទេ។ ប៉ុន្តែទន្ទឹមនឹងនេះដែរ ការថ្លែងរបស់នាយករដ្ឋមន្ត្រីខ្មែរជុំវិញបញ្ហានេះដូចជាការជ្រើសរើសយកកាលៈទេសៈដ៏សមស្ទួន ធ្វើឡើងក្នុងបំណងដែលគេមើលឃើញថាដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់ម្ចាស់ជំនួយអន្តរជាតិឱ្យបានមុនការគោះប្រជុំរវាងរដ្ឋាភិបាលកម្ពុជានិងតំណាងម្ចាស់ជំនួយអន្តរជាតិសម្រាប់កម្ពុជាក្នុងពេលដ៏ខ្លី។**

**ហើយអ្វីគួរឱ្យកត់សម្គាល់ថែមទៀតនោះ គឺមេដឹកនាំកម្ពុជាដូចជាដឹងយ៉ាងច្បាស់ថា ទម្ងន់នៃប្រតិកម្ម ក៏ដូចជាជម្រើសខ្លឹមសារនៃការថ្លែងរបស់តំណាងម្ចាស់ជំនួយអន្តរជាតិដូចជាលែងឱ្យទប់ចិត្តបានមិននិយាយត្រង់ៗចំពោះអំពើពុករលួយនៅកម្ពុជា ទើបបានជាម្ចាស់ជំនួយអន្តរជាតិក្នុងរយៈកាលចុងក្រោយថ្មីៗនេះ បានធ្វើការព្រមានត្រង់ៗថា បើរដ្ឋាភិបាលកម្ពុជាមិនប្រញាប់ធ្វើច្បាប់ប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយចេញយកមកប្រើប្រាស់ឱ្យត្រឹមត្រូវដើម្បីទប់ស្កាត់អំពើពុករលួយទេនោះ គឺម្ចាស់ជំនួយអាចបង្វែជំនួយមួយឆ្នាំៗច្រើនរយលានដុល្លារពីកម្ពុជាទៅជួយប្រទេសក្រីក្រដ៏ទៃទៀតដែលត្រូវការជំនួយនេះដូចកម្ពុជាដែរ។**

**វាមិនមែនជាការលេងសើច ឬក៏មិនមែនជាការយល់សប្តិ ក៏ដូចជាមិនមែនជាភាពចៃដន្យនោះទេ នៅពេលដែលគេបានស្តាប់ឮការថ្លែងរបស់នាយករដ្ឋមន្ត្រីខ្មែរលោក ហ៊ុន សែន ដោយប្រើពាក្យថា អំពើពុករលួយជាឃាតកសម្លាប់រដ្ឋាភិបាល ហើយក៏ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះ។ ហើយនេះគឺជាការកត់សម្គាល់របស់គណបក្សសមរង្ស៊ីដូចការថ្លែងត្រង់ៗរបស់លោក សម រង្ស៊ី ថា រដ្ឋាភិបាលគណបក្សប្រជាជន ទាំងនាយករដ្ឋមន្ត្រី ហ៊ុន សែន នៃរដ្ឋាភិបាលនេះគ្មានសមត្ថភាពនឹងបង្ក្រាបបំបាត់អំពើពុករលួយដែលជាស្នាដៃកើតមានជាមួយការគ្រប់គ្រងប្រទេសរបស់ខ្លួន ហើយក៏ពុំមានឆន្ទៈនឹងបំបាត់អំពើអបាយមុខឧក្រិដ្ឋទាំងនេះ ចំពោះជាតិនិងប្រជារាស្ត្រឯងនោះឡើយ។**

**យ៉ាងណាក៏ដោយ ការមានច្បាប់នេះប្រសើរជាងការមិនមានច្បាប់ នៅត្រង់ថា វាអាចជាគោលមូលដ្ឋានដើម្បីនឹងឱ្យគេតាមដានមើលថា តើអ្នកកាន់អំណាចនៅកម្ពុជាមានឆន្ទៈស្មោះត្រង់ក្នុងការអនុវត្តច្បាប់ដ៏ត្រឹមត្រូវដើម្បីបំបាត់អំពើពុករលួយដែលមួយឆ្នាំៗត្រូវម្ចាស់ជំនួយអន្តរជាតិស្រាវជ្រាវរកឃើញថាធ្វើឱ្យប្រទេសកម្ពុជាដ៏ក្រីក្ររស់ពឹងលើជំនួយអន្តរជាតិ ខាតបាត់បង់ថវិកាច្រើនដល់៣រយ ទៅ៥រយលានដុល្លាររៀងរាល់ឆ្នាំនោះ ឬទេ។ រឿងនេះ ដូចជាកំពុងវិវឌ្ឍន៍ទៅតាមផ្លូវកត់សម្គាល់របស់លោក សម រង្ស៊ី ក៏ដូចជាសមាជិកសភានៃគណបក្សប្រឆាំងដ៏ធំបំផុតរបស់លោកថា ការគ្រប់គ្រងប្រទេសកម្ពុជាដោយគណបក្សប្រជាជន ដែលទទួលខុសត្រូវបង្កើត ឬបណ្តោយឱ្យមានអំពើអបាយមុខពុករលួយនេះ មិនអាចបំបាត់បានឡើយ ដរាបណាប្រទេសកម្ពុជាមិនមានច្បាប់ប្រយុទ្ធប្រឆាំងអំពើពុករលួយដែលមានប្រសិទ្ធិភាពនោះ៕**